ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ជ្រលង

## សម្រាប់រយៈពេល០៣ឆ្នាំ (ខែកុម្ភៈ ឆ្នាំ២០២២-ខែធ្នូ ឆ្នាំ២០២៤)

| | |
|---|---|
| សហគមន៍នេសាទ | ៖ ជ្រលង |
| ភូមិ | ៖ ជ្រលង |
| ភូមិ | ៖ កំពង់ស្អាច់តូច |
| ឃុំ | ៖ ទឹកល្អក់ |
| ស្រុក | ៖ ព្រៃនប់ |
| ខេត្ត | ៖ ព្រះសីហនុ |

ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១

# មាតិកា


**១.ស្ថានភាពទូទៅ** ........ ១

**២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម** ........ ១

ក.ប្រជាពលរដ្ឋ ........ ១

ខ.មុខរបរ ........ ២

**៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........ ២

ក.ទីតាំង ........ ២

ខ.ដែននេសាទ ........ ៣

គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ ៣

ឃ. ធនធានជលផល ........ ៤

១.ប្រភេទត្រី ........ ៤

២.ប្រភេទវារីសត្វ ........ ៤

៣.ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិសមុទ្រ ........ ៤

**៤.ការធ្វើនេសាទ** ........ ៤

ក.អ្នកនេសាទ ........ ៤

ខ.ឧបករណ៍នេសាទ ........ ៤

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........ ៦

**៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ........ ៦

ក.ទស្សនៈវិស័យ ........ ៦

ខ.គោលបំណង ........ ៦

គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ៧

គ.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ ៧

គ.២.ផែនការចុះល្បាត ........ ៨

គ.៣.ផែនការរៀបចំកន្លែងអភិរក្ស ........ ៩

គ.៤.ផែនការគ្រប់គ្រងព្រៃកោងកាង ........ ៩

គ.៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ ១០

គ.៦.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ ........ ១១

គ.៧.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ ........ ១២

គ.៨.ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ ........ ១២

គ.៩.ផែនការបង្កើតស្នាក់ការ និងបណ្ណាល័យសហគមន៍នេសាទ ........ ១៣

គ.១០.ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........ ១៣

ឃ.យុទ្ធសាស្ត្រ ........................................................................................................................................១៤
**៦.ឧបសម្ពន្ធ**
ឧបសម្ពន្ធ ៖តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ២០២២-២០២៤..............................១៥
តារាងកម្មវិធីការងារសម្រាប់សហគមន៍នេសាទក្នុងរយៈពេល០៣ឆ្នាំ២០២២-២០២៤................១៨

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ជ្រលង

## ១.ស្ថានភាពទូទៅ

នៅឆ្នាំ២០០០រដ្ឋបាលជលផលបានធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងវិស័យជលផល ដើម្បីឱ្យសមស្របជាមួយគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការដែលមានក្នុងជាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដោយផ្តោតលើការកាត់បន្ថយភាពក្រីក្រតាមរយៈការផ្ទេរសិទ្ធិអំណាចដល់ប្រជាពលរដ្ឋដែលរស់ជនបទ ដើម្បីចូលរួមគ្រប់គ្រងធនធានជលផលនៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាព និងសមធម៌តាមបែបសហគមន៍នេសាទក្នុងគោលបំណងទទួលផលប្រយោជន៍ និងធ្វើឱ្យធនធានជលផលប្រសើរឡើងនៅមូលដ្ឋានរបស់ខ្លួន។ **ភូមិជ្រលង** និងភូមិ**កំពង់ស្នាច់តូច** ត្រូវបានរៀបចំសហគមន៍នេសាទដោយមានការចូលរួមយ៉ាងកុះករពីប្រជាពលរដ្ឋមូលដ្ឋាន និងបានទទួលការគាំទ្រថវិកាពីរដ្ឋបាលជលផល និងមានកិច្ចសហការពីអាជ្ញាធរដែនដី។ សហគមន៍នេសាទ**ជ្រលង** ត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៥ ដោយបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ និងបានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍លើកទី១ដែលបានអនុវត្តពីខែមិថុនា ឆ្នាំ២០១៨ ដល់ ខែមិថុនា ឆ្នាំ២០២០ ហើយបានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍លើកទី២ ដែលនឹងអនុវត្តចាប់ពីខែកុម្ភៈ ឆ្នាំ២០២២ ដល់ ខែធ្នូ ឆ្នាំ២០២៤។

គណៈកម្មការសហគមន៍នេសាទ ត្រូវបានបោះឆ្នោតដែលមានសមាជិកគណៈកម្មការសហគមន៍នេសាទមានចំនួន០៩នាក់ក្នុងនោះស្ត្រី០១នាក់ ព្រមទាំងបានអនុវត្តតួនាទី និងភារៈកិច្ចរបស់ខ្លួនដែលស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀងកន្លែងនេសាទ និងផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍។ ទន្ទឹមនឹងនេះ គណៈកម្មការសហគមន៍នេសាទបានកសាងសមត្ថភាពតាមរយៈការចូលរួមបណ្តុះបណ្តាល សិក្ខាសាលា ប្រជុំការងារ ទស្សនៈកិច្ចសិក្សា និងរៀនសូត្រតាមឯកសារផ្សេងៗ។

គណៈកម្មការសហគមន៍នេសាទ**ជ្រលង**បានរៀបចំសកម្មភាពសំខាន់ៗ ដើម្បីឱ្យសហគមន៍នេសាទមានផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍សម្រាប់អនុវត្ត និងបង្កលក្ខណៈឱ្យសហគមន៍នេសាទ អាចស្វែងរកថវិកាអនុវត្តការងារសកម្មភាពរបស់ខ្លួន ក្នុងការជួយដល់ការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទសហគមន៍ ព្រមទាំងប្រជាពលរដ្ឋមូលដ្ឋាន ទទួលបានផលប្រយោជន៍ពីការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរ។

## ២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

នៅពេលបច្ចុប្បន្ន ក្នុងឃុំទឹកល្អក់មានចំនួន០៤ភូមិគឺ ភូមិទួល ភូមិព្រែកផ្កាវ ភូមិ**ជ្រលង** និងភូមិកំពង់**ស្នាច់តូច** ដោយឡែកនៅក្នុងសហគមន៍ជ្រលង មានប្រជាពលរដ្ឋសរុបចំនួន៤៩៥គ្រួសារ ក្នុងភូមិ**ជ្រលង**មានចំនួន១៩៥គ្រួសារ ក្នុងនោះស្ត្រីដែលជាមេគ្រួសារមានចំនួន២៥គ្រួសារ និងភូមិកំពង់ស្នាច់តូចមានចំនួន៣០០គ្រួសារ ក្នុងនោះស្ត្រីដែលជាមេគ្រួសារមានចំនួន៤០គ្រួសារ។

ប្រជាជនជាជនជាតិខ្មែរនៅក្នុងសហគមន៍នេសាទនេះ គោរពព្រះពុទ្ធសាសនា ហើយស្ថានភាពទូទៅរបស់ប្រជាជននៅក្នុងភូមិ**ជ្រលង** និងភូមិ**កំពង់ស្នាច់តូច**មានដូចជា៖

- ផ្អែកតាមការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅក្នុងសហគមន៍នេះ បានបង្ហាញថា នៅភូមិជ្រលង គ្រួសារដែលស្ថិតក្នុងក្រីក្រ-២មានចំនួន១៥នាក់ ក្នុងស្ត្រីចំនួន០៥នាក់ និងនៅភូមិកំពង់ស្នាច់តូចមានប្រជាពលរដ្ឋក្រីក្រ-១ មានចំនួន០៥នាក់ ក្នុងនោះស្ត្រីចំនួន០២នាក់ និងមានប្រជាពលរដ្ឋក្រីក្រ-២មានចំនួន២៩នាក់ ក្នុងស្ត្រីចំនួន១៣នាក់។
- ស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមានចំនួន៣០នាក់
- បុរសពោះម៉ាយក្នុងសហគមន៍នេសាទមានចំនួន១០នាក់
- ជនពិការក្នុងសហគមន៍នេសាទមានចំនួន០៧នាក់ ក្នុងនោះស្ត្រីមានចំនួន០៣នាក់
- ចាស់ជរាក្នុងសហគមន៍នេសាទមានចំនួន៦៦នាក់ ក្នុងនោះស្ត្រីមានចំនួន៣៨នាក់
- អ្នកមានជម្ងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមានចំនួន០៦នាក់ ក្នុងនោះស្ត្រីមានចំនួន០៤នាក់
- តាមរបាយការណ៍របស់ក្រុមប្រឹក្សាឃុំ នៅក្នុងសហគមន៍នេសាទជ្រលង និងភូមិកំពង់ស្នាច់តូចបានបង្ហាញថា ៥៣នាក់ដែលមិនចេះអក្សរ ក្នុងនោះស្ត្រីមានចំនួន១៨នាក់។

**ខ.មុខរបរ**

តាមរបាយការណ៍របស់ក្រុមប្រឹក្សាឃុំបានបញ្ជាក់ថា ប្រជាពលរដ្ឋក្នុងសហគមន៍នេះពឹងផ្អែកលើការធ្វើនេសាទ វារីវប្បកម្ម ការធ្វើស្រែ និងការចិញ្ចឹមសត្វ។ ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេស បានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។ រដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីលក្ខណៈគ្រួសារ និងការចិញ្ចឹមសត្វ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងទៀតដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។

ពេលបច្ចុប្បន្ន នៅក្នុងសហគមន៍នេសាទនេះ ប្រជាពលរដ្ឋមានស្ថានភាពនៃការចិញ្ចឹមជីវិត និងមុខរបរសំខាន់ៗរួមមាន៖

| ល.រ | ប្រភេទមុខរបរ | ចំនួនគ្រួសារ | សំគាល់ |
|---|---|---|---|
| ១ | អ្នកមានមុខរបរធ្វើនេសាទ | ៣៤៦ | មុខរបរចំបង |
| ២ | អ្នកចិញ្ចឹមសត្វ និងអ្នកធ្វើស្រែ | ៥០ | |
| ៣ | អ្នកចិញ្ចឹមក្តាមថ្ម | ២១ | (ប=១០មxទ=២,៥មxជ=១,៥ម) |
| ៤ | ចិញ្ចឹមត្រីត្រឡង | ០១ | ចំនួន០៤បៃ |
| ៥ | អ្នកលក់ដូរ | ២៤ | |
| ៦ | ជាងធ្វើទូក និងជួសជុល | ១ | |
| ៧ | អ្នកចិញ្ចឹមត្រីទឹកសាប | ៨ | ៤គ្រួសារ=២ស្រះ និង៤គ្រួសារ=១២គង់ប្លាស្ទិក |
| ៨ | កម្មករ | ១១៥ | |

## ៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

### ក.ទីតាំង

សហគមន៍នេសាទ មានទីតាំងស្ថិតក្នុងភូមិជ្រលង និងភូមិកំពង់ស្មាច់តូចដែលជាដែននេសាទសាធារណៈរបស់រដ្ឋ ហើយជាដែននេសាទសមុទ្រដែលស្ថិតក្នុងឃុំទឹកល្អក់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ សហគមន៍នេសាទនេះ ត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយប្រកាសទទួលស្គាល់នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០។

ដូចនេះ សហគមន៍នេសាទជ្រលងមានព្រំប្រទល់ជាប់នឹង៖

- ខាងជើងជាប់នឹងសហគមន៍នេសាទបឹងរាំង
- ខាងត្បូងជាប់នឹងសហគមន៍នេសាទព្រៃនប់២
- ខាងកើតជាប់នឹងផ្លូវជាតិលេខ៣
- ខាងលិចជាប់នឹងសហគមន៍នេសាទចុងអូរ។

### ខ.ដែននេសាទ

កន្លែងនេសាទសហគមន៍នេសាទជ្រលង មានវិសាលភាពនៅលើដែននេសាទសមុទ្រដែលមានកន្លែងនេសាទទំហំ១,៥៧២ហិកតា ហើយមានកន្លែងអភិរក្សពូជត្រី និងស្មៅសមុទ្រសំខាន់ៗ។

កន្លែងនេសាទសហគមន៍ បានផ្តល់នូវលក្ខណៈងាយស្រួលដល់ការរស់នៅរបស់សហគមន៍មូលដ្ឋាន និងការធ្វើនេសាទសមុទ្ររបស់អ្នកនេសាទខាងក្នុងសហគមន៍ ក៏ដូចជាអ្នកមកពីខាងក្រៅសហគមន៍ ជាពិសេសកន្លែងនេសាទសហគមន៍មានអំណោយផលល្អដល់ការរស់នៅរបស់ពពួកវារីសត្វ រុក្ខជាតិសមុទ្រ ជាពិសេសប្រភេទវារីសត្វ និងរុក្ខជាតិសមុទ្រជាចំណី និងជម្រកពងកូនរបស់មច្ឆា សត្វស្លាប និងសត្វល្មូនគ្រប់ប្រភេទ។ ជាក់ស្តែង កន្លែងនេសាទសហគមន៍បានភ្ជាប់ជាមួយសមុទ្រ ហើយទឹកសមុទ្រមានលក្ខណៈជោរ និងនាចដែលបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទនេះ។

### គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

សហគមន៍នេសាទជ្រលងបានសម្រេចបង្កើតកន្លែងអភិរក្សចំនួន០២កន្លែង ដែលមានទំហំប្រហែល៣៥ហិកតា ហើយជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ ផ្កាថ្ម និងក្រែមឈាម។ ដូចនេះផងដែរ កន្លែងអភិរក្សត្រូវបានធ្វើការគ្រប់គ្រងដោយសហគមន៍ ហើយកន្លែងអភិរក្សទាំងពីរនេះ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះកន្លែងអភិរក្ស | ទំហំជាហិកតា | ការអភិរក្ស |
|---|---|---|---|
| ១ | កន្លែងអភិរក្សកោះកុកប្រហែល | ០៥ | ប្រភេទត្រីមេពូជ |
| ២ | កន្លែងអភិរក្សកោះក្អាមប្រហែល | ៣០ | ប្រភេទស្មៅសមុទ្រ និងក្អាម |
| | សរុប | ៣៥ | |

### ឃ.ធនធានជលផល

នៅក្នុងប្រទេសកម្ពុជា ធនធានជលផលបានដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង ដោយឡែកត្រីអាចផ្តល់ជាអាហារដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ។ តាមការបង្ហាញពីសហគមន៍បានឱ្យដឹងថាពេលបច្ចុប្បន្ន ធនធានជលផលក្នុងសមុទ្រមិនមានការកើនឡើងទេ ដោយសារមានការប្រែប្រួលអាកាសធាតុ និងកត្តាមនុស្ស។ ផ្អែកតាមការអង្កេតរបស់ក្រុមការងារ និងសមាជិកសហគមន៍បានបង្ហាញថា ធនធានជលផលក្នុងសហគមន៍នេសាទជ្រលងមានប្រភេទវារីសត្វ និងរុក្ខជាតិសមុទ្រដូចជា៖

#### ឃ.១.ប្រភេទត្រីសមុទ្រ:

ក្នុងសហគមន៍នេសាទ មានប្រភេទត្រីដូចជា៖ ត្រីឆ្កង់ ត្រីក្បក ត្រីអាំងកីយ ត្រីចង្កោមបី ត្រីដំឡូង ត្រីប្លាធូ ត្រីក្តចិន ត្រីស្តុងក្រហម ត្រីផ្ទោង ត្រីត្រសក់ ត្រីឆ្លាម ត្រីការ៉ាវ ត្រីប្រម៉ា ត្រីកិ ត្រីកន្ទង ត្រីកាម៉ុង ត្រីក្បាលឡានត្រីអណ្តែងប៉ុយ ត្រីកន្តាំង ត្រីកន្ទុយរឹង ត្រីកាបាស ត្រីបបែល ត្រីឆ្លាត ត្រីក្អុក ត្រីបាលង្គ ត្រីកាឡាំង ត្រីអង្រែ ត្រីគូន ត្រីសេក ត្រីតក់កែ ត្រីផ្ទក់សមុទ្រ ត្រីសេះ។ល។

#### ឃ.២.ប្រភេទវារីសត្វសមុទ្រ

ក្នុងសហគមន៍នេសាទ មានប្រភេទវារីសត្វដូចជា៖ បង្កង បង្គា ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ មឹក គ្រែងឈាម ងាវភក់ ហូល ងាវស បង្កងប៉ាក អណ្តើក កន្ធាយ បាលង្កកាស កញ្ជ អន្ទង់ ខ្ចឹង។ល។

#### ឃ.៣.ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិ

ក្នុងសហគមន៍នេសាទ មានប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិដូចជា៖ ផ្កាថ្ម ស្មៅសមុទ្រ និងព្រៃកោងកាង។

## ៤.ការធ្វើនេសាទ

តាមការសិក្សា និងប្រមូលទិន្នន័យពីក្រុមប្រឹក្សាឃុំ ភូមិ និងសហគមន៍បានបង្ហាញថា ចំនួនអ្នកដែលពាក់ព័ន្ធក្នុងការធ្វើនេសាទលើកន្លែងនេសាទសហគមន៍មានដូចខាងក្រោម៖

#### ៤.ក.អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន២២៩នាក់ ក្នុងនោះស្ត្រីមានចំនួន១០៧នាក់។
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន២៤៧នាក់ ក្នុងនោះស្ត្រីមានចំនួន៩៨នាក់។
- តាមការប៉ាន់ស្មានអ្នកនេសាទដែលមកពីខាងក្រៅ ហើយមិនមែនជាសមាជិកដែលជាសហគមន៍មានប្រហែល៦០គ្រួសារ ក្នុង១ឆ្នាំ។

#### ៤.ខ.ឧបករណ៍នេសាទ

ការនេសាទក្នុងដែនសហគមន៍នេសាទ គណៈកម្មការ និងសមាជិកសហគមន៍ បានធ្វើការប៉ាន់ប្រមាណពីតម្រូវការប្រភេទឧបករណ៍នេសាទដែលស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។ ម្យ៉ាងវិញទៀត គណៈកម្មការ និងសមាជិកសហគមន៍នេសាទទាមទារឱ្យសមត្ថកិច្ចជំនាញជលផលធ្វើការផ្សព្វផ្សាយច្រើនដងដល់ប្រជាពលរដ្ឋក្នុសហគមន៍ និង

អ្នកនេសាទខាងក្រៅលើប្រភេទឧបករណ៍នេសាទដែលហាមឃាត់។ ដូចនេះ ប្រភេទឧបករណ៍នេសាទ ទូក និង ការណូតរបស់សមាជិកសហគមន៍ដែលបានប្រើប្រាស់ក្នុងសហគមន៍នេះ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ/ចំនួន | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងត្រីក្បក | ម៉ែត្រ | ៩០ | ពេញមួយឆ្នាំ |
| ២ | មងត្រីតារាវ | ម៉ែត្រ | ៣៥០ | ពេញមួយឆ្នាំ |
| ៣ | លបក្ដាមសេះ | លប | ២៥០ | ពេញមួយឆ្នាំ |
| ៤ | លបក្ដាម | លប | ៥០០ | ពីខែ១២ ដល់ ខែ០១ |
| ៥ | សន្ទូចត្រីក្អុក | ផ្លែ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ៦ | មងក្ដាម | ម៉ែត្រ | ១៧៥ | ពីខែ១១ ដល់ ខែ០១ |
| ៧ | មងត្រីកន្លាំង | ម៉ែត្រ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ៨ | សន្ទូចត្រីអន្ទែងប៉ុយ | ផ្លែ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ៩ | មងត្រីឆ្កង | ម៉ែត្រ | ៣៥០ | ពីខែ១០ ដល់ ខែ០៤ |
| ១០ | សន្ទូចបបែល | ផ្លែ | ៥០០ | ពីខែ០៤ ដល់ ខែ០៧ |
| ១១ | ឈិបរុញដោយដៃ | គ្រឿង | ៣ម ទៅ៥ម | ពីខែ០១ ដល់ ខែ១២ |

| ល.រ | ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|---|
| ១ | ទូកម៉ាស៊ីន | ២៦ | ៧០០ | ៦ ដល់ ១៣ |
| ២ | ទូកចែវ | ១៣ | | |

ឧបករណ៍នេសាទ ទូក និងកាណូតរបស់អ្នកខាងក្នុងសហគមន៍នេសាទតែមិនមែនជាសមាជិក

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ/ចំនួន | រដូវនេសាទ |
|---|---|---|---|---|
| ១ | លបក្ដាមសេះ | លប | ២៥០ | ពេញមួយឆ្នាំ |
| ២ | មងត្រីក្បក | ម៉ែត្រ | ៩០ | ពេញមួយឆ្នាំ |
| ៣ | មងត្រីតារាវ | ម៉ែត្រ | ៣៥០ | ពេញមួយឆ្នាំ |
| ៤ | លបក្ដាម | លប | ៥០០ | ពីខែ១២ ដល់ ខែ០១ |
| ៥ | សន្ទូចត្រីក្អុក | ផ្លែ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ៦ | មងក្ដាម | ម៉ែត្រ | ១៧៥ | ពីខែ១១ ដល់ ខែ០១ |
| ៧ | មងត្រីកន្លាំង | ម៉ែត្រ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ៨ | សន្ទូចត្រីអន្ទែងប៉ុយ | ផ្លែ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ៩ | មងត្រីឆ្កង | ម៉ែត្រ | ៣៥០ | ពីខែ១០ ដល់ ខែ០៤ |
| ១០ | សន្ទូចបបែល | ផ្លែ | ៥០០ | ពីខែ០៤ ដល់ ខែ០៧ |
| ១១ | ឈិបរុញដោយដៃ | គ្រឿង | ៣ម ទៅ៥ម | ពីខែ០១ ដល់ ខែ១២ |

| ល.រ | ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|---|
| ១ | កាណូត | ២១ | ៧០០ | ៦ ដល់ ១៣ |
| ២ | ទូកចែវ | ៥ | | |

ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ/ចំនួន | រដូវនេសាទ |
|---|---|---|---|---|
| ១ | លបក្តាមសេះ | លប | ២៥០ | ពេញមួយឆ្នាំ |
| ២ | លបក្តាម | លប | ៥០០ | ពីខែ១២ ដល់ ខែ០១ |
| ៣ | មងក្តាម | ម៉ែត្រ | ១៧៥ | ពីខែ១១ ដល់ ខែ០១ |
| ៤ | មងត្រីឆ្កង | ម៉ែត្រ | ៣៥០ | ពីខែ១០ ដល់ ខែ០៤ |
| ៥ | ឈិបរុញដោយដៃ | គ្រឿង | ៣ម ទៅ៥ម | ពីខែ០១ ដល់ ខែ១២ |

| ល.រ | ប្រភេទទូកកាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|---|
| ១ | កាណូត | ៥០ | ១០០០ | ៦ ដល់ ១៣ |

គ.ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ល.រ | ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជាគក្រ) | | |
|---|---|---|---|---|
| | | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ១ | ត្រីគ្រប់ប្រភេទ | ១៥១ | ១៨៧ | ៣៣៨ |
| ២ | បង្គា | ១៣៥ | ២១៥ | ៣៥០ |
| ៣ | ក្តាម | ៩៨ | ១២២ | ២២០ |
| ៤ | មឹក ខ្យង និងគ្រែងឈាម | ៧៥ | ១០៥ | ១៨០ |
| **សរុប** | | **៤៥៩** | **៦២៩** | **១០៨៨** |

## ៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ក.ទស្សនៈវិស័យ

សហគមន៍នេសាទ មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ.គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទសមុទ្រជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ ធ្វើនេសាទទំនាបលិចទឹកក្នុងរដូវទឹកជោរ ព្រៃកោងកាង និងកន្លែងអភិរក្ស។

- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍន៍ចំរុះ។
- ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ច្បាស់ហើយឈានទៅចាត់ទុកថា ខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

## គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ

**គោលបំណង**

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺ រៀបចំឡើងដោយបានគិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ រដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងដែននេសាទ ដោយធ្វើយ៉ាងណាមិនឱ្យការធ្វើនេសាទលើសពីតម្រូវការធនធានជលផលដែលមានក្នុងកន្លែងសហគមន៍។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងសហគមន៍ ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ/ចំនួន | រដូវនេសាទ |
|---|---|---|---|---|
| ១ | លបក្តាមសេះ | លប | ២៥០ | ពេញមួយឆ្នាំ |
| ២ | មងត្រីក្បក | ម៉ែត្រ | ៩០ | ពេញមួយឆ្នាំ |
| ៣ | មងត្រីតាវ | ម៉ែត្រ | ៣៥០ | ពេញមួយឆ្នាំ |
| ៤ | មងត្រីផ្ទោង | ម៉ែត្រ | ១៥០ | ពេញមួយឆ្នាំ |
| ៥ | លបក្តាម | លប | ៥០០ | ពីខែ១២ ដល់ ខែ០១ |
| ៦ | មងបង្គា | ម៉ែត្រ | ១៥០ | ពីខែ១២ ដល់ ខែ០១ |
| ៧ | មងក្តាម | ម៉ែត្រ | ១៧៥ | ពីខែ១១ ដល់ ខែ០១ |
| ៨ | មងត្រីកន្តាំង | ម៉ែត្រ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ៩ | មងត្រីការម៉ុង | ម៉ែត្រ | ២៥០ | ពីខែ០៤ ដល់ ខែ០៦ |
| ១០ | មងត្រីគូន | ម៉ែត្រ | ៣០ | ពីខែ០៩ ដល់ ខែ១២ |
| ១១ | មងត្រីឆ្កង | ម៉ែត្រ | ៣៥០ | ពីខែ១០ ដល់ ខែ០៤ |
| ១២ | សន្ទូចបបែល | ផ្លែ | ៥០០ | ពីខែ០៤ ដល់ ខែ០៧ |
| ១៣ | សន្ទូចត្រីក្អុក | ផ្លែ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ១៤ | សន្ទូចត្រីអន្តែងប៉ុយ | ផ្លែ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ១៥ | ឈិបរុញបង្គាស្មើជើង | គ្រឿង | ៣ម ទៅ៥ម | ពីខែ០១ ដល់ ខែ១២ |

ទីតាំង ឬកន្លែងនេសាទ

| ល.រ | ឈ្មោះទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | |
|---|---|---|---|---|
| | | | ប្រភេទ | ទំហំ/ប្រវែង |
| ១ | កន្លែងនេសាទសហគមន៍ | តាមប្រភេទត្រី | លប មង សន្ទូច ឈិបរុញ ។ល។ | លេខ៣១៩ប្រក.កសក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ |

**សំគាល់:** ត្រូវអនុវត្តតាមប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ៣១៩ ប្រក.កសក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកំណត់ប្រភេទឧបករណ៍ដែលអនុញ្ញាតិឱ្យធ្វើនេសាទក្នុងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។

**គ.២.ផែនការចុះល្បាត**

ជាទូទៅ ការចុះល្បាត ជាភារកិច្ចរបស់គណៈកម្មការ និងសមាជិកសហគមន៍ ប៉ុន្តែ ការចុះល្បាតនេះគឺផ្អែកលើការជួយឧត្ថម្ភពីដៃគូអភិវឌ្ឍន៍។ កន្លងមក ការចុះល្បាតលើកន្លែងនេសាទសហគមន៍បានអនុវត្តតិចតួច ពីព្រោះថា ខ្វះមធ្យោបាយល្បាត។ គណៈកម្មការ និងសមាជិកសហគមន៍នេសាទ បានរៀបចំផែនការល្បាតក្នុងគោលបំណងដូចជា៖

- ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់
- សមាជិកអាចទទួលបានផលនេសាទពីកន្លែងនេសាទសហគមន៍
- គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព។

ផែនការល្បាត ដើម្បីទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(រៀល) | អ្នកចូលរួម | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១ | ប្រជុំពិភាក្សាលើការរៀបចំផែនការល្បាត | ៥០០ ០០០ | គណៈកម្មការ ជំនាញជលផល | ២០២២ | ២០២៤ |
| ២ | រៀបចំមធ្យោបាយ និងសម្ភារៈ<br>• សាំង និងប្រេងបាត<br>• អាវភ្លៀង អាវពោង ពិល មួក<br>• កាតទូរស័ព្ទ អាយកូមទាក់ទង<br>• ទូកម៉ាស៊ីន | ៩ ០០០ ០០០ | គណៈកម្មការ ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០២២ | ២០២៤ |
| ៣ | ប្រជុំផ្សព្វផ្សាយផែនការល្បាតដល់អ្នកពាក់ព័ន្ធ | ៥០០ ០០០ | ជំនាញជលផល អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ | ២០២២ | ២០២៤ |
| ៤ | អនុវត្តផែនការ និងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ជលផល និងជំនាញពាក់ព័ន្ធ | ៣ ៥០០ ០០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | ២០២២ | ២០២៤ |

ទីតាំង ឬកន្លែងនេសាទ

| ល.រ | ឈ្មោះទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | |
|---|---|---|---|---|
| | | | ប្រភេទ | ទំហំ/ប្រវែង |
| ១ | កន្លែងនេសាទសហគមន៍ | តាមប្រភេទត្រី | លប មង សន្ទូច ឈិបរុញ ។ល។ | លេខ៣១៩ប្រក.កសក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ |

**សំគាល់:** ត្រូវអនុវត្តតាមប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ៣១៩ ប្រក.កសក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកំណត់ប្រភេទឧបករណ៍ដែលអនុញ្ញាតិឱ្យធ្វើនេសាទក្នុងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។

គ.២.ផែនការចុះល្បាត

ជាទូទៅ ការចុះល្បាត ជាភារកិច្ចរបស់គណៈកម្មការ និងសមាជិកសហគមន៍ ប៉ុន្តែ ការចុះល្បាតនេះគឺផ្អែកលើការជួយឧត្ថម្ភពីដៃគូអភិវឌ្ឍន៍។ កន្លងមក ការចុះល្បាតលើកន្លែងនេសាទសហគមន៍បានអនុវត្តតិចតួចពីព្រោះថា ខ្វះមធ្យោបាយល្បាត។ គណៈកម្មការ និងសមាជិកសហគមន៍នេសាទ បានរៀបចំផែនការល្បាតក្នុងគោលបំណងដូចជា៖

- ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់
- សមាជិកអាចទទួលបានផលនេសាទពីកន្លែងនេសាទសហគមន៍
- គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព។

ផែនការល្បាត ដើម្បីទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(រៀល) | អ្នកចូលរួម | ថ្ងៃ/ខែ/ឆ្នាំចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| ១ | ប្រជុំពិភាក្សាលើការរៀបចំផែនការល្បាត | ៥០០ ០០០ | គណៈកម្មការ ជំនាញជលផល | ២០២២ | ២០២៤ |
| ២ | រៀបចំមធ្យោបាយ និងសម្ភារៈ<br>• សាំង និងប្រេងបាត<br>• អាវភ្លៀង អាវពោង ពិល មួក<br>• កាតទូរស័ព្ទ អាយកូមទាក់ទង<br>• ទូកម៉ាស៊ីន | ៩ ០០០ ០០០ | គណៈកម្មការ ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០២២ | ២០២៤ |
| ៣ | ប្រជុំផ្សព្វផ្សាយផែនការល្បាតដល់អ្នកពាក់ព័ន្ធ | ៥០០ ០០០ | ជំនាញជលផល អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ | ២០២២ | ២០២៤ |
| ៤ | អនុវត្តផែនការ និងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ជលផល និងជំនាញពាក់ព័ន្ធ | ៣ ៥០០ ០០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | ២០២២ | ២០២៤ |

### គ.៣.ផែនការរៀបចំកន្លែងអភិរក្ស

គណៈកម្មការ និងសមាជិកសហគមន៍នេសាទ បានសម្រេចបង្កើតកន្លែងអភិរក្សចំនួន០២កន្លែងគឺ កន្លែងអភិរក្សកោះកុក និងកន្លែងអភិរក្សកោះក្អាម ដែលជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ និងផ្កាថ្ម។ ដូចនេះផងដែរ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទ ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយកន្លែងអភិរក្សត្រីមេពូជទាំងពីរនេះបង្កើតឡើងក្នុងគោលបំណងដូចជា៖

- បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ
- ថែរក្សាការពារព្រៃកោងកាងដែលជាទីជម្រក ប្រភពចំណីរបស់ត្រី និងសត្វ
- ផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋឱ្យចេះស្រឡាញ់ថែរក្សា និងការពារធនធានធម្មជាតិ
- ជាពិសេស ធនធានជលផល បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

តាមការចុះអង្កេតរបស់ក្រុមការងារ និងពិភាក្សាលើលក្ខណៈវិនិច្ឆ័យជាមួយគណៈកម្មការ និងសមាជិកសហគមន៍បានបញ្ជាក់ថា កន្លែងអភិរក្សកោះកុកដែលមានទំហំ០៥ហិកតា និងកន្លែងអភិរក្សកោះក្អាមមានទំហំ៣០ហិកតា ដែលជាកន្លែងសំខាន់បំផុតសម្រាប់ធ្វើការអភិរក្សត្រីមេពូជផ្កាថ្ម និងគ្រែមឈាមដែលសមាជិសហគមន៍នេសាទមានសុឆន្ទៈចង់ចូលរួមក្នុងការគ្រប់គ្រងធនធានជលផល ដើម្បីធានានូវប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានជលផល និងជាប្រយោជន៍សម្រាប់តម្រូវការផលត្រីរបស់ប្រជាពលរដ្ឋក្នុងសហគមន៍។ ដូចនេះ ផែនការរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះទីតាំង | ទំហំ (ហត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| កន្លែងអភិរក្ស កោះកុក | ០៥ | • ប្រភេទត្រីសំខាន់<br>• ប្រភេទផ្កាថ្ម<br>• ប្រភេទសារាយ<br>• ប្រភេទពពួកល្មូន | • ផ្សព្វផ្សាយអ្នកពាក់ព័ន្ធ<br>• សិក្សាពីកន្លែងអភិរក្ស<br>• បង្គោលស៊ីម៉ង់០៦ដើម<br>• ធ្វើប៉ាណូផ្សព្វផ្សាយ<br>• សង់រោងយាម<br>• ចុះល្បាតជាប្រចាំ | ២០២២ | ២០២៤ |
| កន្លែងអភិរក្ស កោះក្អាម | ៣០ | ប្រភេទគ្រែងឈាម | | ២០២២ | ២០២៤ |

### គ.៤.ផែនការគ្រប់គ្រងព្រៃកោងកាង

ព្រៃកោងកាង បានគ្របដណ្តប់លើដែននេសាទសហគមន៍ជ្រលងដែលមានទំហំប្រហែល៣២០ហិកតា ដោយបានផ្តល់នូវសក្តានុពល និងសារៈប្រយោជន៍ជាច្រើនដល់ប្រភេទត្រីសត្វល្មូន ប្រភេទសត្វ និងវារីសត្វផ្សេងៗ សម្រាប់ជាជម្រករស់នៅបង្កកំណើតកូន និងជាចំណីផងដែរ។ ផែនការគ្រប់គ្រងព្រៃកោងកាង ត្រូវបានរៀបចំឡើងក្នុងគោលបំណងដូចជា៖

- ថែរក្សា ការពារព្រៃកោងកាងឱ្យនៅគង់វង្សយូរអង្វែងដល់ក្មេងជំនាន់ក្រោយ។
- ទុកជាជម្រកត្រី វារីសត្វគ្រប់ប្រភេទ ជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ទប់ស្កាត់ការហូរច្រោះទឹករលក និងជារបាំងខ្យល់។

• បង្កើនទិន្នផលត្រី និងពពួកសត្វមានជីវិតគ្រប់ប្រភេទឱ្យសំបូរឡើង ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍។

គណៈកម្មការ និងសមាជិកសហគមន៍នេសាទ**ជ្រលង**បានកំណត់ បែងចែកព្រៃកោងកាង កន្លែងអភិរក្ស និងកន្លែងប្រើប្រាស់ព្រៃកោងកាងដោយផ្អែកតាមផែនទីសហគមន៍នេសាទ។ កន្លែងប្រើប្រាស់ព្រៃកោងកាងត្រូវអប់រំណែនាំដល់ប្រជាពលរដ្ឋឱ្យចេះកាប់រំលោះមែកដែលធ្វើយ៉ាងណាមិនឱ្យងាប់ដើម ដើម្បីយកមកប្រើប្រាស់ជាអុសចំអិនអាហារ។

ផែនការគ្រប់គ្រងព្រៃកោងកាង ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះទីតាំង | ទំហំ (ហត) | ប្រភេទកូនឈើដែលត្រូវការពារ | សកម្មភាព | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ថែរក្សា និងការពារព្រៃកោងកាង | ៣២០ | ព្រៃកោងកាង | • ផ្សព្វផ្សាយផែនការគ្រប់គ្រងព្រៃកោងកាង<br>• បោះបង្គោល<br>• ដាក់ស្លាកសញ្ញាការពារ<br>• ត្រួតពិនិត្យ និងការពារ | ២០២២ | ២០២៤ |

**គ.៤.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម**

ក្រៅពីនេសាទត្រី ការចិញ្ចឹមត្រីជាមុខរបរចំបងរបស់ប្រជានេសាទនៅក្នុងសហគន៍**ជ្រលង**។ ជាទូទៅប្រជាពលរដ្ឋក្នុងសហគមន៍នេសាទនេះ ច្រើនចិញ្ចឹមត្រីតាមបែបដែលការចិញ្ចឹមត្រីសមុទ្រមានដូចជា៖ ត្រីឆ្កង និងក្តាមថ្ម។ល។ ការចិញ្ចឹមត្រី ជាទម្លាប់របស់ប្រជាពលរដ្ឋកម្ពុជាជាយូរឆ្នាំមកហើយ ដោយអ្នកខ្លះចាប់បានពូជត្រីពីធម្មជាតិ អ្នកខ្លះទៀតចិញ្ចឹមដូចលក្ខណៈប្រស់ ឬចិញ្ចឹមបំប៉នឱ្យមានទំហំសមស្របសម្រាប់តម្រូវការទីផ្សារ។

ការចិញ្ចឹមត្រី ជាទិសដៅដ៏សំខាន់របស់វិស័យជលផល ក្នុងការបង្កើនត្រីសាច់សម្រាប់ហូបចុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងសម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចេញប្រកាសលេខ ៣២៥ប្រក កសកស្តីពី ការគ្រប់គ្រងការចិញ្ចឹមត្រីរស់ ត្រីឆ្តោរ ដែលស្របនឹងតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋាន។ ដូចនេះផងដែរ សហគមន៍នេសាទ**ជ្រលង** បានផ្តោតសំខាន់លើការចិញ្ចឹមត្រីមានដូចជា ការចិញ្ចឹមត្រីទឹកសាប ការចិញ្ចឹមត្រីត្រីឆ្កង និងក្តាមថ្ម ពីព្រោះសហគមន៍នេះស្ថិតជាប់នឹងសមុទ្រ។ ការអភិវឌ្ឍន៍វារីវប្បកម្មរបស់សហគមន៍នេសាទ**ជ្រលង**ក្នុងគោលបំណងដូចជា៖

• បង្កើនត្រីសាច់សម្រាប់ហូបចុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
• បង្កើនប្រាក់ចំណូលដែលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ
• កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។

ឆ្លើយតបទៅនឹងការអភិវឌ្ឍន៍វារីវប្បកម្ម គណៈកម្មការ និងសមាជិកសហគមន៍នេសា**ជ្រលង** បានចូលរួមរៀបចំផែនការអភិវឌ្ឍន៍វារីវប្បកម្ម ដូចមានក្នុងតារាងខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទកូនពូជ | បរិមាណកូនត្រី | ថ្ងៃ/ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីឆ្តុងតាមបច្ចេកទេសជាលក្ខណៈគ្រួសារក្នុងបែចំនួន២០គ្រួសារ | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើបែចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ២០បែ | កូនត្រីឆ្តុង | ៥០០ក្បាល/គ្រួសារ | ២០២២ | ២០២៤ |
| ចិញ្ចឹមក្តាមថ្ម តាមបច្ចេកទេសជាលក្ខណៈគ្រួសារចំនួន០៦គ្រួសារ | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើកន្លែងចិញ្ចឹម<br>• ផ្តល់កូន<br>• តាមដានត្រួតពិនិត្យ | ទំហំដី១០អា/គ្រួសារ | កូនក្តាមថ្ម | ៩០០/ក្បាល/គ្រួសារ | ២០២២ | ២០២៤ |

**គ.៦.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ**

ពេលបច្ចុប្បន្ន សហគមន៍នេសាទជ្រលង បានរៀបចំផែនការកន្លែងកំសាន្តនៅកន្លែងមាត់សមុទ្រដែលជាដែននេសាទរបស់សហគមន៍នេសាទ ដែលអាចជួយកាត់បន្ថយអត្រាចំណាកស្រុករបស់សមាជិកសហគមន៍នេសាទ និងកាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង ដើម្បីចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព។ ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍ជ្រលង ក្នុងគោលបំណងដូចជា៖

- បង្កើនប្រាក់ចំណូលដែលជួយស្តួយសេដ្ឋកិច្ចគ្រួសារ
- ជួយកាត់បន្ថយអត្រាចំណាកស្រុករបស់សមាជិកសហគមន៍នេសាទ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត
- កាត់បន្ថយអត្រាការប្រាក់ខ្ពស់ និងខ្ចីប្រាក់ពីឈ្មួញ
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង។

ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភពថវិកា | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| រៀបចំកន្លែងកំសាន្តសម្រាប់សហគមន៍នេសាទជ្រលង | • ផ្សព្វផ្សាយសមាជិកសហគមន៍<br>• ការរៀបចំក្រុមសម្រាប់អនុវត្ត<br>• បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• បណ្តុះបណ្តាលពីការរៀបចំឯកសារ<br>• ត្រួតពិនិត្យតាមដាន | គាំទ្រដោយដៃគូរអភិវឌ្ឍ | ២០២២ | ២០២៤ |

| សកម្មភាព | អ្នកទទួលខុសត្រូវ | រយៈពេលអនុវត្ត ២០២២-២០២៤ | | | តម្លៃប៉ាន់ស្មាន (គិតជារៀល) | ប្រភពទុន |
|---|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | | |
| ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ | រដ្ឋបាលជលផល | ៤ | ៤ | ៤ | ១ ៥០០ ០០០ | រដ្ឋបាលជលផល ដៃគូអភិវឌ្ឍន៍ រដ្ឋបាលឃុំ |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | ស.ន | ៤ | ៤ | ៤ | ១ ០០០ ០០០ | |

**គ.៩.ផែនការបង្កើតស្នាក់ការ និងបណ្ណាល័យសហគមន៍នេសាទ**

ពេលបច្ចុប្បន្ន សហគមន៍នេសាទជ្រលង ពុំទាន់មានស្នាក់ការនៅឡើយ ហើយគណៈកម្មការមានការលំបាកក្នុងពេលបំពេញការងារក៏ដូចជា ការងារទំនាក់ទំនងជាមួយក្រុមការងារផ្សេងៗ ឬភ្ញៀវទេសចរណ៍ជាដើម។ ដូច្នេះ ស្នាក់ការនិងបណ្ណាល័យ គួរត្រូវបានបង្កើតឡើងនិងបំពាក់សម្ភារៈមួយចំនួនដូចជា៖ តុ កៅអី និងទូឯកសារ ។ គម្រោងស្នាក់ការ និងបណ្ណាល័យ ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| សកម្មភាព | ទីតាំងគម្រោង | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ | តម្លៃប៉ាន់ស្មាន (រៀល) | ប្រភពទុន |
|---|---|---|---|---|---|
| គម្រោងស្នាក់ការ | គណៈកម្មការសហគមន៍ | ២០២២ | ២០២៤ | ១១ ០០០ ០០០ | រាជរដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន |
| គម្រោងបណ្ណាល័យ | | ២០២២ | ២០២៤ | ៤ ០០០ ០០០ | |

**គ.១០.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ**

ដោយឡែក គណៈកម្មការសហគមន៍នេសាទ ដើរតួនាទីសំខាន់ក្នុងការស្វែងរកប្រាក់ចំណូលពីប្រភពផ្សេងៗដូចជា៖ វិភាគទានពីសមាជិកសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ សប្បុរសជន ក្រុមប្រឹក្សាឃុំ និងការធ្វើទស្សនៈកិច្ចរបស់ភ្ញៀវមកក្នុងសហគមន៍នេសាទ។ ដូចនេះ ផែនការស្វែងរកថវិកាសម្រាប់ទ្រង់សហគមន៍ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ប្រភេទចំណូល | សកម្មភាព | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ | ចំណូល (រៀល) |
|---|---|---|---|---|---|
| ១ | វិភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍ | ប្រជុំផ្សព្វផ្សាយ និងបណ្ណវិភាគទាន | ២០២២ | ២០២៤ | ១ ៥០០ ០០០ |
| ២ | ពីអ្នកនេសាទខាងក្រៅ ឬអ្នកមិនមែនជាសមាជិក | ចេញបណ្ណវិភាគទាន | ២០២២ | ២០២៤ | ៣ ០០០ ០០០ |
| ៣ | សប្បុរសជន និងអង្គការដៃគូអភិវឌ្ឍន៍ | • បង្កើតមុខរបរ<br>• ជាថវិកាផ្ទាល់ | ២០២២ | ២០២៤ | ៤ ០០០ ០០០ |
| ៤ | ក្រុមប្រឹក្សាឃុំ | ធនធានធម្មជាតិ | ២០២២ | ២០២៤ | ១ ៥០០ ០០០ |

ឃ.យុទ្ធសាស្ត្រ

នៅក្នុងសហគមន៍នេសាទ ត្រូវរៀបចំយុទ្ធសាស្ត្រ ដើម្បីឱ្យការអនុវត្តផែនការទទួលបានជោគជ័យ។ យុទ្ធសាស្ត្រទាំងនេះមានដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តន៍ផែនការរួមមាន៖ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទដែលមានបទពិសោធន៍ និងចំណេះដឹងល្អជាពិសេសអំពីបញ្ហានេសាទ។
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា៖ ការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃកោងកាង កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម។
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោងនិងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ។
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់។
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ។
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគោការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ។
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍។
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ។
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ។
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ជ្រលងរយៈពេល០៣ឆ្នាំ (ខែកុម្ភៈ ឆ្នាំ២០២២- ខែធ្នូ ឆ្នាំ២០២៤)**

| ប្រភេទផែនការ/សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ(រៀល) | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ |
|---|---|---|---|---|---|
| **១.ផែនការប្រើប្រាស់ឧបណ៍នេសាទ** | • កាត់បន្ថយទំនាស់នេសាទក្នុងកន្លែងនេសាទ<br>• កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់<br>• សហគមន៍នឹងអនុវត្តន៍ប្រកាសស្ដីពីការប្រើប្រាស់ឧបករណ៍ | **១ ៨០០ ០០០** | | ២០២២ | ២០២៤ |
| ១.១.ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារក្នុង១ឆ្នាំ/៤ដង | សមាជិកនឹងយល់ដឹងការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារ | ១ ៨០០ ០០០ | អង្គការដៃគូសប្បុរសជនរដ្ឋាភិបាល | | |
| ១.២.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | ឧបករណ៍នេសាទនឹងបានផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | | | | |
| ១.៣.ត្រួតពិនិត្យ និងតាមដាន | គណៈកម្មការ និងសមាជិកចូលរួមឃ្លាំមើល និងរាយការណ៍ | | | | |
| **២.ផែនការចុះល្បាត** | •ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់<br>•សមាជិកអាចទទួលបានផលនេសាទពីកន្លែងនេសាទសហគមន៍<br>•គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព | **១៣ ០០០ ០០០** | | | |
| ២.១.ប្រជុំពិភាក្សាលើការរៀបចំផែនការល្បាត | ផែនការល្បាតបានពិគ្រោះយោបល់ និងរៀបចំសម្រាប់អនុវត្ត | ៥០០ ០០០ | | ២០២២ | ២០២៤ |
| ២.២.រៀបចំមធ្យោបាយ និងសម្ភារៈ | មធ្យោបាយ និងសម្ភារៈបានគ្រោងនិងរៀបចំ | ៩ ០០០ ០០០ | | | |
| ២.៣.ប្រជុំផ្សព្វផ្សាយផែនការល្បាតដល់អ្នកពាក់ព័ន្ធ | ផែនការល្បាតនឹងត្រូវបានផ្សព្វផ្សាយដល់សមាជិកសហគមន៍ | ៥០០ ០០០ | | | |
| ២.៤.អនុវត្តផែនការចុះល្បាត | ផែនការចុះល្បាតនឹងត្រូវបានអនុវត្ត | ៣ ៥០០ ០០០ | | | |
| **៣.ផែនការរៀបចំកន្លែងអភិរក្ស** | •ប្រភេទត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទត្រូវបានធ្វើការអភិរក្ស<br>•ប្រភេទព្រៃកោងកាងនឹងត្រូវបានការពារ<br>•ប្រជាជននឹងយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស | **៩ ០០០ ០០០** | | | |
| ៣.១.បោះបង្គោលស៊ីម៉ង់កន្លែងអភិរក្សកោះកុក និងកោះក្ដាម | ចំនួន១២បង្គោលនឹងបានបោះនៅកន្លែងអភិរក្សទាំងពីរដោយមានផែនទីសំគាល់កន្លែងអភិរក្ស | ៤ ០០០ ០០០ | | ២០២២ | ២០២៤ |
| ៣.២.ផ្សព្វផ្សាយដល់ប្រជាជន | ប្រជាជននឹងយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស | ២០០ ០០០ | អង្គការដៃគូសប្បុរសជនរដ្ឋាភិបាល | ២០២២ | ២០២៤ |
| ៣.៣.ផលិតផ្ទាំងប៉ាណូផ្សព្វផ្សាយ | ចំនួន០១ស្លាកផ្ទាំងប៉ាណូ នឹងបោះសម្រាប់ផ្សព្វផ្សាយ | ១ ២០០ ០០០ | | | |
| ៣.៤.សង់រោងយាម | រោងយាមចំនួន០១ត្រូវបានសាងសងនៅកន្លែងអភិរក្សទំហំ៤មx៥ម | ១ ៨០០ ០០០ | | | |
| ៣.៥.ចុះល្បាតជាប្រចាំ | បទល្មើសនេសាទនឹងថយចុះតាមរយៈការចុះល្បាត | ១ ៨០០ ០០០ | | | |

| | | | | | |
|---|---|---|---|---|---|
| **៤.ផែនការគ្រប់គ្រងព្រៃកោងកាងទំហំ៣២០ហិកតា** | •សមាជិកសហគមន៍យល់ដឹងពីសារៈប្រយោជន៍ព្រៃកោងកាង<br>•ព្រៃកោងកាងត្រូវបានការពារដោយសមាជិកសហគមន៍នេសាទ | **២ 000 000** | | | |
| ៤.១.ប្រជុំផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃកោងកាង | សមាជិកសហគមន៍យល់ដឹងពីសារៈប្រយោជន៍ព្រៃកោងកាង | ២00 000 | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ៤.២.ថែរក្សា និងការពារព្រៃកោងកាង | ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ និងដាក់ស្លាកសញ្ញាការពារ | ៨00 000 | | | |
| ៤.៣.ចុះល្បាតជាប្រចាំ | សកម្មភាពកាប់បំផ្លាញព្រៃកោងកាងនឹងត្រូវបានទប់ស្កាត់ | ១ 000 000 | | | |
| **៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម** | •បង្កើនត្រីសាច់សម្រាប់ហូបចុកក្នុងមូលដ្ឋាន<br>•រកប្រាក់ចំណូលជួយស្តួយសេដ្ឋកិច្ចគ្រួសារ<br>•កាត់បន្ថយសម្ពាធនេសាទលើធនធានជលផលហួសកំរិត។ | **៩ 000 000** | | | |
| **៥.១.ចិញ្ចឹមត្រីឆ្តុងតាមបច្ចេកទេសជាលក្ខណៈគ្រួសារក្នុងបេ ចំនួន២០គ្រួសារ** | | **៣ 000 000** | | | |
| ៥.១.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន២០គ្រួសារត្រូវបានជ្រើសរើស | ៣ 000 000 | ដៃគូរអភិវឌ្ឍន៍<br>សប្បុរសជន<br>រដ្ឋាភិបាល | ២០២២ | ២០២៤ |
| ៥.១.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីឆ្តុង | ចំនួន២០គ្រួសារ នឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីឆ្តុង | | | | |
| ៥.១.៣.ធ្វើបេចិញ្ចឹមត្រីឆ្តុង | ចំនួន២០បេដែលក្នុង១បេទំហំ៥មx៣មx២,៥ម ត្រូវបានសាងសង់ | | | | |
| ៥.១.៤.ការដាក់កូនត្រីក្នុងបេ | ចំនួនកូនត្រី៥០០កូននឹងត្រូវបានផ្តល់ក្នុងមួយគ្រួសារ | | | | |
| ៥.១.៥.ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន២០គ្រួសារ នឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៥.២.ចិញ្ចឹមក្តាមថ្មតាមបច្ចេកទេសជាលក្ខណៈគ្រួសារ ចំនួន០៦គ្រួសារ** | | **៦ 000 000** | | | |
| ៥.២.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន០៦គ្រួសារត្រូវបានជ្រើសរើស | ៦ 000 000 | ដៃគូរអភិវឌ្ឍន៍<br>សប្បុរសជន<br>រដ្ឋាភិបាល | ២០២២ | ២០២៤ |
| ៥.២.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម | ចំនួន០៦គ្រួសារ នឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម | | | | |
| ៥.២.៣.ធ្វើកន្លែងចិញ្ចឹម | កន្លែងចិញ្ចឹមត្រូវបានរៀបចំ | | | | |
| ៥.២.៤.ការដាក់កូន | កូនក្តាមថ្មចំនួន៩០០ក្បាលនឹងត្រូវបានផ្តល់ក្នុង០១គ្រួសារ | | | | |
| ៥.២.៥.ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន០៦គ្រួសារ នឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៦.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ** | • បង្កើនប្រាក់ចំណូលដែលជួយស្តួយសេដ្ឋកិច្ចគ្រួសារ<br>• កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត<br>• ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួន | **១១ ៦00 000** | | | |
| ៦.១.ផ្សព្វផ្សាយទស្សនៈដល់សមាជិកសហគមន៍ | ទស្សនៈទាននឹងផ្សព្វផ្សាយដល់សមាជិកសហគមន៍ | ១១ ៦00 000 | ដៃគូរអភិវឌ្ឍន៍<br>សប្បុរសជន | ២០២២ | ២០២៤ |
| ៦.២.បង្កើតក្រុមសម្រាប់អនុវត្ត | ក្រុមការងារនឹងត្រូវបានបង្កើត | | | | |
| ៦.៣.រៀបចំគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង | គោលការណ៍ និងបទបញ្ជាផ្ទៃក្នុងនឹងត្រូវបានរៀបចំ | | | | |

| | | | | | |
|---|---|---|---|---|---|
| ៦.៤.បណ្តុះបណ្តាលពីការរៀបចំឯកសារ និងថវិកា | សមាជិកក្រុមការងារ នឹងបានបណ្តុះបណ្តាល | | រដ្ឋាភិបាល | | |
| ៦.៥.ត្រួតពិនិត្យតាមដាន | ក្រុមការងារនឹងធ្វើការត្រួតពិនិត្យ និងកែលម្អ | | | | |
| **៧.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ** | •គណៈកម្មការនឹងអាចអនុវត្តសកម្មភាពក្នុងការងារ<br>•យល់ពីតួនាទី និងភារកិច្ចរបស់ពួកគាត់<br>•បង្កើនសាមគ្គីភាព និងការទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធ | **១ ៧០០ ០០០** | | | |
| ៧.១.បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេររបាយការណ៍ និងលិខិតរដ្ឋបាល | កំណត់ហេតុ សរសេររបាយការណ៍ និងលិខិតរដ្ឋបាល នឹងត្រូវបានបណ្តុះបណ្តាល | ៤០០ ០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២២ |
| ៧.២.បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ការគ្រប់គ្រងថវិកា នឹងត្រូវបានបណ្តុះបណ្តាល | ៣០០ ០០០ | | ២០២២ | ២០២២ |
| ៧.៣.បណ្តុះបណ្តាលការដោះស្រាយទំនាស់ | វិធីសាស្ត្រដោះស្រាយទំនាស់នឹងត្រូវបានបណ្តុះបណ្តាល | ៤០០ ០០០ | | ២០២៣ | ២០២៣ |
| ៧.៤.បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ជំនាញសម្របសម្រួលនឹងត្រូវបានបណ្តុះបណ្តាល | ២០០ ០០០ | | ២០២៣ | ២០២៣ |
| ៧.៥.បណ្តុះបណ្តាលការរៀបចំផែនការ | ការរៀបចំផែនការ នឹងត្រូវបានបណ្តុះបណ្តាល | ៤០០ ០០០ | | ២០២៤ | ២០២៤ |
| **៨.ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ** | • បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ<br>• កាត់បន្ថយសកម្មភាពបទល្មើសនេសាទ | **៣ ០០០ ០០០** | | | |
| ៨.១.ផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ | ច្បាប់ជលផល និងលិខិតបទដ្ឋាន នឹងត្រូវបានផ្សព្វផ្សាយ | ២ ០០០ ០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ៨.២.ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង នឹងត្រូវបានផ្សព្វផ្សាយ | ១ ០០០ ០០០ | | | |
| **៩.ផែនការបង្កើតស្នាក់ការ និងបំពាក់សម្ភារៈ** | | **១៥ ០០០ ០០០** | | | |
| ៩.១.ការបង្កើតស្នាក់ការ | ស្នាក់ការរបស់សហគមន៍នឹងត្រូវសាងសង់ | ១១ ០០០ ០០០ | អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ៩.២.ការបំពាក់សម្ភារៈ | សម្ភារៈកៅអី និងទូឯកសានឹងត្រូវបានបំពាក់ | ៤ ០០០ ០០០ | | | |
| **១០.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ** | | **១០ ០០០ ០០០** | | | |
| ១០.១.វិភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍ | វិភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍ | ១ ៥០០ ០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ១០.២.ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ៣ ០០០ ០០០ | | | |
| ១០.៣.អំណោយពីសប្បុរសជន និងអង្គការដៃគូ | សប្បុរសជន និងអង្គការដៃគូអភិវឌ្ឍន៍ | ៤ ០០០ ០០០ | | | |
| ១០.៤.ក្រុមប្រឹក្សាឃុំ | មូលនិធិរបស់ឃុំ | ១ ៥០០ ០០០ | | | |

# តារាងកម្មវិធីការងារសម្រាប់សហគមន៍នេសាទប្រលងក្នុងរយៈពេល០៣ឆ្នាំ (ខែកុម្ភៈ ឆ្នាំ២០២២- ខែធ្នូ ឆ្នាំ២០២៤)

| សកម្មភាព | ២០២២ | | | | | | | | | | | ២០២៣ | | | | | | | | | | | | ២០២៤ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខែនីមួយៗ | | | | | | | | | | | ខែនីមួយៗ | | | | | | | | | | | | ខែនីមួយៗ | | | | | | | | | | | |
| | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១.ការប្រើប្រាស់ឧបករណ៍នេសាទក្នុងដែននេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.ផែនការចុះល្បាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.ផែនការរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤.ផែនការគ្រប់គ្រងព្រៃកោងកាង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.ផែនការពង្រឹងសមត្ថភាពគណៈកម្មការនិងសមាជិក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៨.ផែនការផ្សព្វផ្សាយច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩.ផែនការបង្កើតស្នាក់ការសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១០.ការកថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

សូមគោរពជូន
លោកមេឃុំទឹកល្អក់
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ...... ខែទុសាឍឆ្នាំឆ្លូវត្រីស័ក,ព ស២៥៦៥
......ថ្ងៃទី...២១...ខែ...កក្កដា...ឆ្នាំ២០២១
**ប្រធានគណៈកម្មការសហគមន៍នេសាទ**
**ជ្រលង**

លេខៈ......../២១
បានឃើញ និង គោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលកំពង់ស្មាច់
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ...... ខែទុសាឍឆ្នាំឆ្លូវត្រីស័ក,ព ស២៥៦៥
ថ្ងៃទី...២១...ខែ...កក្កដា...ឆ្នាំ២០២១
**មេឃុំ**
ជួន ស៊ុនហេង

បានឃើញ និង គោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលព្រែនប់
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ...... ខែទុសាឍឆ្នាំឆ្លូវត្រីស័ក,ព ស២៥៦៥
ថ្ងៃទី...២១...ខែ...កក្កដា...ឆ្នាំ២០២១
**នាយសង្កាត់រដ្ឋបាលជលផលកំពង់ស្មាច់**

បានឃើញ និង គោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់សោម
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ...... ខែទុសាឍឆ្នាំឆ្លូវត្រីស័ក,ព ស២៥៦៥
ថ្ងៃទី...២១...ខែ...កក្កដា...ឆ្នាំ២០២១
**នាយផ្នែករដ្ឋបាលជលផលព្រែនប់**

លេខៈ........
បានឃើញ និង គោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះសីហនុ
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ...... ខែ......ឆ្នាំឆ្លូវ ត្រីស័ក,ព ស២៥៦៥
......ថ្ងៃទី...២២...ខែ...កក្កដា...ឆ្នាំ ២០២១
**នាយខណ្ឌរដ្ឋបាលជលផលកំពង់សោម**
ឯម ឆា.

លេខ......../២១
បានឃើញ និង គោរពជូន
ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល
ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ
ថ្ងៃ...... ខែ...... ឆ្នាំឆ្លូវត្រីស័ក,ព ស២៥៦៥
......ថ្ងៃទី ...... ខែ...... ឆ្នាំ ២០២១
**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះសីហនុ**
**អនុប្រធាន**
គីក_ជីវ៉ាយ

លេខ........
បានឃើញ និងឯកភាព
ថ្ងៃ...... ខែ......ឆ្នាំឆ្លូវត្រីស័ក,ព ស២៥៦៥
រាជធានីភ្នំពេញ .ថ្ងៃទី......ខែ......ឆ្នាំ២០២១
**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**
ពុំ សុថា